**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

**សុន្ទរកថា**
**ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**
**ថ្លែងក្នុងឱកាសបិទកិច្ចប្រជុំពេញអង្គ**
**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០២១**
**ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ តាមបណ្ដាញវីដេអូ កម្មវិធី ZOOM**

ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ដែលកំពុងមានវត្តមានដ៏ឧត្តុង្គឧត្តម តាមបណ្ដាញវីដេអូ នាពេលនេះ!

ឆ្លងកាត់នូវការចំណាយពេលដ៏មានតម្លៃពេញមួយព្រឹក កិច្ចប្រជុំពេញអង្គរបស់យើងបានធ្វើបទបង្ហាញ រួមជាមួយនឹងការពិភាក្សា និងផ្ដល់យោបល់យ៉ាងផុលផុស ដែលនាំឱ្យយើងទទួលបាននូវលទ្ធផលគួរជាទីមោទនៈ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី!**

ទោះបីជាយើងធ្វើការពិភាក្សាតាមបណ្ដាញវីដេអូក៏ពិតមែន តែដោយសារតែមានការចូលរួមយ៉ាងសកម្មពី ឯកឧត្តម លោកជំទាវ លោក លោកស្រី បានធ្វើឱ្យពេលវេលាដ៏មានតម្លៃរបស់យើងអាចទទួលបាននូវផ្លែផ្កា ដែលខ្ញុំសូមយកឱកាសនេះ សម្ដែងនូវការកោតសរសើរដ៏ស្មោះស្ម័គ្របំផុតជូន សមាជិក សមាជិកានៃអង្គពិធីទាំងមូល។

ខ្ញុំសូមអនុញ្ញាតឆ្លៀតឱកាសមុនបិទកិច្ចប្រជុំពេញអង្គរបស់យើង ផ្ដល់ជូននូវចំណាប់អារម្មណ៍បូកសរុបលទ្ធផលជារួមដែលទទួលបានពីកិច្ចប្រជុំនេះ ដោយខ្ញុំសូមរំឭកអង្គពិធីទាំងមូលអំពីកិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្នុងការរៀបចំដំណើរឆ្លងកាត់ពីអន្តរកាលឆ្ពោះទៅរកចីរភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ក៏ដូចជាការធ្វើឱ្យសម្រេចគោលដៅរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការប្ដេជ្ញាបញ្ចប់ជំងឺអេដស៍ដែលជាការគំរាមកំហែងសុខភាពសាធារណៈ នៅឆ្នាំ២០២៥ខាងមុខដូចតទៅ ៖

១) ជារួម យើងទាំងអស់គ្នាពិតជាបានខិតខំអនុវត្តផែនការសកម្មភាព រយៈពេល៦ខែដើមឆ្នាំ២០២១ នៅតាមក្រសួង ស្ថាប័នជាតិ អន្តរជាតិ សង្គមស៊ីវិល ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ដោយសារតែការគំរាមកំហែងពីជំងឺកូវីដ-១៩ លទ្ធផលដែលយើងទទួលគឺអាចខុសៗគ្នាទៅតាមស្ថានភាពជាក់ស្តែងរបស់ស្ថាប័ននីមួយៗ។

២) សូមលើកទឹកចិត្តគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត ឱ្យបន្តជំរុញ និងចូលរួមសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសអាជ្ញាធរឃុំ សង្កាត់ ក្នុងការអនុវត្ត "សេចក្តីជូនដំណឹងលេខ ២១៣ សជណ.សស" ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រីក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅថ្នាក់ក្រោមជាតិ។

៣) យើងត្រូវខិតខំធ្វើការសិក្សាស្វែងយល់ ពិនិត្យ និងបង្កើនលទ្ធភាព និងប្រសិទ្ធភាពក្នុងការផ្សព្វផ្សាយស្តីពី ការបង្ការការចម្លងមេរោគអេដស៍ក្នុងចំណោមក្រុមប្រឈម ក្នុងបរិបទកូវីដ-១៩ នេះ ដែលនៅតែមានការកើនឡើងគួរឱ្យព្រួយបារម្ភ។ យើងត្រូវពង្រឹកសេវាគ្របដណ្តប់ ក្នុងការផ្តល់ប្រឹក្សា និងទាក់ទាញក្រុមប្រឈមនោះឱ្យមកទទួលសេវាថែទាំ និងព្យាបាល។

ជាមួយគ្នានេះផងដែរ ខ្ញុំសូមផ្តល់ជូននូវអនុសាសន៍មួយចំនួនដូចខាងក្រោម ៖

១) ទាំងអស់គ្នា សូមចូលរួមអនុវត្តសេចក្តីសម្រេចចិត្តនៃកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០២១ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ដែលកិច្ចប្រជុំពេញអង្គទើបបានអនុម័តយល់ព្រមនាពេលអម្បាញ់មិញនេះ។

២) អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវប្រមូលរាល់អនុសាសន៍ទាំងអស់ដែលបានអនុម័តជាគោលការណ៍នៅក្នុងកិច្ចប្រជុំនេះ ដើម្បីយកទៅរៀបចំ និងកែលម្អសម្រាប់ដាក់ចេញនូវគម្រោងផែនការសកម្មភាពក្នុងពេលខាងមុខ។

៣) បន្តជំរុញ និងលើកទឹកចិត្តក្រសួង ស្ថាប័នដែលពុំទាន់បានទទួលថវិកាពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យលើកសំណើថវិកាឆ្នាំ២០២២ក្នុងកញ្ចប់ផែនការថវិការបស់ក្រសួង ស្ថាប័នសាមីឱ្យបានព្រមៗគ្នា។

៤. បន្តជំរុញ និងកែសម្រួលនូវកម្មវិធីគ្រួសារក្រីក្រ ដោយបញ្ចូលអ្នកផ្ទុកមេរោគអេដស៍និងជំងឺអេដស៍ទៅក្នុងប្រព័ន្ធចុះឈ្មោះមន្ទីរពេទ្យបង្អែក (PMRs) នៅតាមបណ្តារាជធានី ខេត្ត។

៥. បន្តការអប់រំផ្សព្វផ្សាយឱ្យកាន់តែទូលាយ ដើម្បីជំរុញការធ្វើតេស្តរកមេរោគអេដស៍។

៦. ជំរុញនិងពង្រឹងការគ្រប់គ្រងទិន្នន័យនៃការឆ្លើយតបនឹងមេរោគអេដស៍ នៅថ្នាក់រាជធានី ខេត្ត ចំនួនអ្នកផ្ទុកមេរោគអេដស៍ អត្រាឆ្លងថ្មី អត្រាស្លាប់ ចំនួនអ្នកបោះបង់ការព្យាបាល ចំនួនប្រជាជនគន្លឹះ និងការកាត់បន្ថយអត្រាឆ្លងមេរោគអេដស៍ពីម្តាយទៅកូន។

៧. រៀបចំនូវផែនការសកម្មភាពនៃ ទីក្រុងពន្លឿនសកម្មភាពឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដោយយកខេត្តបាត់ដំបងជាគំរូ។

៨. បន្តកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ដើម្បីទទួលបានជំនួយទាំងសម្ភារ ថវិកា និងបច្ចេកទេស សម្រាប់និរន្តរភាពកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍នៅកម្ពុជា រហូតសម្រេចបានជោគជ័យនៅឆ្នាំ២០២៥។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី!**

មុននឹងបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ដែលបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំពេញអង្គដ៏មានសារៈសំខាន់ នាពេលនេះ។ តាមរយៈការចូលរួមយ៉ាងសកម្ម ផ្តល់នូវគំនិតល្អៗ រួមជាមួយនឹងមតិដ៏ល្អ និងមានតម្លៃ នាំឱ្យយើងអាចយកទៅប្រើប្រាស់ក្នុងការកែលម្អការអនុវត្តការងារប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍ឱ្យកាន់តែមានប្រសិទ្ធភាពថែមមួយកម្រិតទៀត។

ខ្ញុំសូមសម្តែងនូវការកោតសរសើរផងដែរចំពោះ អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលបានខិតខំរៀបចំកិច្ចប្រជុំពេញអង្គនេះឱ្យប្រព្រឹត្តទៅបានដោយរលូន និងសម្រេចបាននូវផ្លែផ្កាគួរជាទីមោទនៈនាពេលនេះ។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ នូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងជៀសផុតពីជំងឺកូវីដ-១៩ បានគ្រប់ៗគ្នា និងសូមប្រកាសបិទ **"កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០២១"** ចាប់ពីពេលនេះតទៅ។

**សូមអរគុណ!**